**SPACE**
Strengthening Performance, Accountability and Civic Engagement

# ឯកសារប្រឹក្សាយោបល់

## ស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

EU-Program to support the National Program for Sub National Democratic Development of NCDD

implemented by giz

**មាតិកា**

សេចក្តីផ្តើម ii
គោលបំណង ii
រចនាសម្ព័ន្ធនៃឯកសារប្រឹក្សាយោបល់ iii
សេចក្តីផ្តើមពីមូលដ្ឋានគ្រឹះនៃការប្រឹក្សាយោបល់ 1
មេរៀនតម្រង់ទិស និងការព្រមព្រៀងជាមួយក្រុមគោលដៅទៅលើប្រធានបទ និងកម្មវិធីសម្រាប់ការប្រឹក្សាយោបល់ 2
ផ្នែកទី១ ៖ ការត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា 7
មេរៀនទី១ ៖ ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ (ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី១ និងទី២) 8
មេរៀនទី២ ៖ ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ (ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី១ និងទី២) 11
មេរៀនទី៣ ៖ ការធ្វើលិខិតអញ្ជើញ និងផ្សព្វផ្សាយសេចក្តីព្រាងរបៀបវារៈនិងឯកសារពាក់ព័ន្ធនានា (ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី៣) 16
ផ្នែកទី២ ៖ ការដំណើរការកិច្ចប្រជុំក្រុមប្រឹក្សា 18
មេរៀនទី១ ៖ ការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៣ និងទី៤) 19
មេរៀនទី២ ៖ តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៣ និងទី៤) 20
មេរៀនទី៣ ៖ ការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្ត (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៦) 21
មេរៀនទី៤ ៖ តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងដំណើការពិភាក្សានិងការធ្វើសេចក្តីសម្រេចលើបញ្ហានានា (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៦) 23
មេរៀនទី៥ ៖ សំណួរចម្លើយ និងការបញ្ចេញមតិយោបល់ (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៧) 24
មេរៀនទី៦ ៖ សំណួរ ចម្លើយនិងការបញ្ចេញមតិយោបល់ (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៧) 26
មេរៀនទី៧ ៖ បញ្ហាផ្សេងៗ (ផ្នែកទី២ ជំហានទី៨) 28
មេរៀនទី៨ ៖ កិច្ចប្រជុំសម្ងាត់ និងកិច្ចប្រជុំវិសាមញ្ញ 30

## សេចក្តីផ្តើម

ស្របជាមួយនឹងការចាប់ផ្តើមនៃការអនុវត្តន៍ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅ ខែ ឧសភា ឆ្នាំ២០០៨ នឹងការបង្កើតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនៅឆ្នាំ២០០៩ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាមានតំណាងរបស់ខ្លួននៅគ្រប់កំរិត។

ដូចបានរៀបរាប់ខាងលើ តំណាងទាំងនោះមានឈ្មោះថាក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនឹងតំណាងអោយប្រជាពលរដ្ឋ ព្រមទាំងមានគណនេយ្យភាព និងឆ្លើយតបចំពោះប្រជាពលរដ្ឋមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីបំពេញតួនាទី ក្នុងការអនុវត្ត មុខងាររបស់ពួកគេ។ ដើម្បីឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិអនុវត្តមុខងាររបស់ខ្លួនប្រកបដោយគណនេយ្យភាព រាល់ក្រុមប្រឹក្សាថ្នាក់ ក្រោមជាតិទាំងអស់ត្រូវរៀបចំកិច្ចប្រជុំយ៉ាងហោចណាស់១២ដងក្នុងមួយឆ្នាំដើម្បីពិភាក្សាអំពីបញ្ហានានា កត្តាប្រឈមនិងការអភិវឌ្ឍមូលដ្ឋាន។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុម ប្រឹក្សាអាចប្រជុំវិសាមញ្ញ ក៏ដូចជាកិច្ចប្រជុំសម្ងាត់ តាមការចាំបាច់។ អង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ។

ក្នុងគោលបំណងដើម្បីគាំទ្រដល់ក្រុមប្រឹក្សាដើម្បីរៀបចំ និងដំណើការកិច្ចប្រជុំរបស់ពួកគេប្រកបដោយការឆ្លើយតប និងសកម្ម គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយមានការគាំទ្រពីកម្មវិធីសហភាពអឺរ៉ុបដើម្បីលើកកំពស់ការបំពេញការងារគណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ បានបង្កើត ឯកសារប្រឹក្សាយោបល់ស្តីអំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីអោយ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ប្រើប្រាស់ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាក្នុងការរៀបចំ និងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

## គោលបំណង

គោលបំណងនៃឯកសារប្រឹក្សាយោបល់ស្តីអំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គឺដើម្បីជួយដល់ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ក្នុងការគាំទ្រដល់ក្រុមប្រឹក្សាក្នុងការរៀបចំ និងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ឯកសារនេះជាឯកសារបន្ថែមទៅលើឯកសារបច្ចេកទេសសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីផ្តល់ការប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានាប្រកប ដោយប្រសិទ្ធភាព។

## រចនាសម្ព័ន្ធនៃឯកសារប្រឹក្សាយោបល់

ឯកសារប្រឹក្សាយោបល់នេះត្រូវបានរៀបចំជារចនាសម្ព័ន្ធដូចខាងក្រោម ៖

- **សេចក្តីណែនាំអំពីគោលគំនិតនៃការប្រឹក្សាយោបល់:** ជួយដល់ក្រុមគោលដៅបានយល់ដឹងអំពីគោលគំនិតនៃការប្រឹក្សាយោបល់ ។
- **មេរៀនតម្រង់ទិស:** នឹងផ្តល់ដល់អ្នកចូលរួមនូវទិដ្ឋភាពទូទៅនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងព្រមព្រៀងគ្នាជាមួយក្រុមគោលដៅទៅលើប្រធានបទ និងកម្មវិធីសម្រាប់ការប្រឹក្សាយោបល់ ។
- **ផ្នែកទី១ ៖ ការ ត្រៀមរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា:** ពិពណ៌នាពីវិធីសាស្ត្រ និងដំណើរការ ក្នុងការគាំទ្រដល់ក្រុមគោលដៅ ដោយផ្តោតជាសំខាន់ទៅលើការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈសម្រាប់កិច្ចប្រជុំ និងសារៈសំខាន់នៃការធ្វើលិខិតអញ្ជើញ និងការផ្សព្វផ្សាយសេចក្តីព្រាងរបៀបវារៈ និង ឯកសារពាក់ព័ន្ធទៅអ្នកចូលរួមកិច្ចប្រជុំក្នុងរយៈពេលសមស្របមុនកិច្ចប្រជុំ ។ ផ្នែកនេះមានបីមេរៀន ៖

  មេរៀនទី១ ៖ ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ ( ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផ្នែកទី១ ជំហានទី១ និងទី២ សម្រាប់សមាជិកក្រុមប្រឹក្សាទាំងមូល)

  មេរៀនទី២ ៖ ការរៀបចំសេចក្តីព្រាងរបៀបវារៈ និងឯកសារពាក់ពន្ធ័សម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផ្នែកទី១ ជំហានទី១ និងទី២ សម្រាប់ប្រធានក្រុមប្រឹក្សា គណៈអភិបាល និងនាយករដ្ឋបាល)

  មេរៀនទី៣ ៖ ការរៀបចំលិខិតអញ្ជើញ សេចក្តីព្រាងរបៀបវារៈ និង ឯកសារផ្សេងៗ (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផ្នែកទី១ ជំហានទី៣ សម្រាប់គណៈអភិបាល និងនាយករដ្ឋបាល)
- **ផ្នែកទី២ ៖ ដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា:** ពិពណ៌នាពីវិធីសាស្ត្រ និងដំណើរការដែលជួយដល់អ្នកប្រឹក្សាយោបល់ក្នុងការគាំទ្រដល់ក្រុមគោលដៅក្នុងដំណើរការកិច្ចប្រជុំ ។ ផ្នែកនេះមាន៨មេរៀន ៖

  មេរៀនទី១ ៖ ការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផ្នែកទី២ ជំហានទី៣ និងទី៤ សម្រាប់សមាជិកក្រុមប្រឹក្សាទាំងមូល)

  មេរៀនទី២ ៖ តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុង ការសម្របសម្រួលលើការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន (ឯកសារបច្ចេកទេសស្តីពី កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផ្នែកទី២ ជំហានទី៣ និងទី៤ សម្រាប់ប្រធានក្រុមប្រឹក្សា)

  មេរៀនទី៣ ៖ ការពិភាក្សា និងការធ្វើសេចក្តីសម្រេច លើបញ្ហានានា (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្នែកទី២ ជំហានទី៦ សម្រាប់សមាជិកក្រុមប្រឹក្សាទាំងមូល)

  មេរៀនទី៤ ៖ តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុង ដំណើការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្តលើបញ្ហានានា (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ផ្នែកទី២ ជំហានទី៦ សម្រាប់ប្រធានក្រុមប្រឹក្សា)

មេរៀនទី៥ ៖ កម្មវិធីសំណួរ-ចម្លើយ និងការបញ្ចេញមតិយោបល់ (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្នែកទី២ ជំហានទី៧ សំរាប់សមាជិកក្រុមប្រឹក្សាទាំងមូល)

មេរៀនទី៦៖ កម្មវិធីសំណួរ-ចម្លើយ និងការបញ្ចេញមតិយោបល់ (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្នែកទី២ ជំហានទី៧ សម្រាប់ប្រធានក្រុមប្រឹក្សា និងនាយករដ្ឋបាល)

មេរៀនទី៧៖ បញ្ហាផ្សេងៗ (ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្នែកទី២ ជំហានទី៨ សម្រាប់ប្រធានក្រុមប្រឹក្សា និងនាយករដ្ឋបាល)

មេរៀនទី៨៖ កិច្ចប្រជុំសម្ងាត់ និងកិច្ចប្រជុំវិសាមញ្ញ (សម្រាប់សមាជិកក្រុមប្រឹក្សាទាំងមូល និងនាយករដ្ឋបាល)

## សេចក្តីណែនាំអំពីគោលគំនិតនៃការប្រឹក្សាយោបល់

| ប្រធានបទ | សេចក្តីណែនាំពីគោលគំនិតនៃការប្រឹក្សាយោបល់ | **សម្ភារៈ និងឯកសារយោង** |
|---|---|---|
| **គោលបំណង** | នៅចុងបញ្ចប់មេរៀននេះក្រុមគោលដៅនឹងអាចយល់ដឹងអំពីគោលគំនិតនៃការប្រឹក្សាយោបល់ | |
| **ក្រុមគោលដៅ** | ក្រុមប្រឹក្សាទាំងមូល គណៈអភិបាល និងនាយករដ្ឋបាល | |
| **រយៈពេល** | ១ម៉ោង១៥នាទី | |
| **ដំណើការ**<br>**១ម៉ោង១៥ នាទី** | **សេចក្តីផ្តើម (៥នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់គួរ ពន្យល់ថា មានវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពផ្សេងៗ។ យោងទៅលើផែនការអនុវត្តពាឆ្នាំ (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ វិធីសាស្ត្រសម្រាប់អភិវឌ្ឍសមត្ថភាពសំខាន់ៗរួមមាន: **ការបណ្តុះបណ្តាល ការសម្របសម្រួល ការប្រឹក្សាយោបល់ ការផ្តល់ប្រឹក្សា ការសិក្សាកំរិតឧត្តម ទស្សនៈកិច្ចសិក្សា សិក្ខាសាលាពេញអង្គ និងការឆ្លុះបញ្ចាំង។**<br>ការប្រឹក្សាយោបល់ គឺជាវិធីសាស្ត្រមួយដែលមានសារៈសំខាន់ក្នុងការជួយដល់ក្រុមគោលដៅបង្កើតជម្រើសផ្សេងៗដើម្បីអភិវឌ្ឍការងារ។<br>**សំណួរបំផុស (១០នាទី)**<br>- មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរៈ តើការប្រឹក្សាយោបល់ (Coaching)ជាអ្វី?<br>- មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ផ្តល់ឱកាសដល់អ្នកចូលរួម៣ទៅ៤នាក់ដើម្បីចែករំលែក នូវការយល់ដឹងរបស់ពួកគេអំពីនិយមន័យនៃការប្រឹក្សាយោបល់។ | |
| | **បទបង្ហាញ (១ម៉ោង)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បង្ហាញពីគោលគំនិតនៃការប្រឹក្សាយោបល់៖<br>- និយមន័យការប្រឹក្សាយោបល់<br>- គោលបំណងនៃការប្រឹក្សាយោបល់<br>- ភាពខុសគ្នារវាង ការផ្តល់ប្រឹក្សាបច្ចេកទេស (Expert Advice) និងការប្រឹក្សាយោបល់ (Coaching) | បទបង្ហាញទី១ គោលគំនិតនៃការប្រឹក្សាយោបល់ |

**ចំណាំ៖** មេរៀននេះនឹងរៀបចំមុនមេរៀនតម្រង់ទិសចាប់ផ្តើម

**មេរៀនតម្រង់ទិស និងការព្រមព្រៀងទៅលើប្រធានបទ និងកម្មវិធីសម្រាប់ការប្រឹក្សាយោបល់**

| ប្រធានបទ | ការតម្រង់ទិស និងការព្រមព្រៀងទៅលើប្រធានបទ និងកម្មវិធីសម្រាប់ការប្រឹក្សាយោបល់ | **សម្ភារៈ និង ឯកសារយោង** |
|---|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹង ៖<br>- យល់ពីទិដ្ឋភាពទូទៅនៃឯកសារបច្ចេកទេស<br>- ព្រមព្រៀងលើប្រធានបទ និងកម្មវិធីសម្រាប់ការប្រឹក្សាយោបល់ដើម្បីគាំទ្រដល់ការត្រៀមរៀបចំ និងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា | |
| **អ្នកចូលរួម** | សមាជិកក្រុមប្រឹក្សាទាំងមូល គណៈអភិបាល និងនាយករដ្ឋបាល | |
| **រយៈពេល** | ៣ម៉ោង១៥នាទី | |
| **ដំណើរការ ៣ម៉ោង** | **ការណែនាំ និងមតិស្វាគមន៍ (១៥នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់មានមតិស្វាគមន៍ដោយបញ្ជាក់ថា កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជារបបប្រជុំមួយទៀងទាត់ ដែលសមាជិកក្រុមប្រឹក្សាទាំងអស់ជួបជុំគ្នាដើម្បីពិភាក្សាចាត់អាទិភាព និងរកដំណោះ ដើម្បីធ្វើសេចក្តីសម្រេច ទៅលើបញ្ហានានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយរួមមានការបែងចែកធនធាន ដែលមានកំណត់ របស់ខ្លួនដើម្បីឆ្លើយតបទៅនឹង បញ្ហាជាអាទិភាព នានារបស់ប្រជាពលរដ្ឋ ។<br><br>**បទបង្ហាញពីគោលបំណង និងកម្មវិធីតម្រង់ទិស**<br>**សំណួរបំផុស (១៥នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សួរសំណួរដូចខាងក្រោម ៖<br>- តើមានជំហានអ្វីខ្លះក្នុងការរៀបចំ និងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សង្ខេបចម្លើយរបស់សិក្ខាកាមលើក្រដាសផ្ទាំងធំ ។<br><br>**ការពិភាក្សាពេញអង្គ(១ម៉ោង)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ បង្ហាញពីទិដ្ឋភាពទូទៅនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដោយបង្ហាញពីផ្ទាំងរូបភាពទី១ និងទី២ និងយោងទៅ លើឯកសារបច្ចេកទេសស្តីអំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ បញ្ជាក់ពីជំហាននីមួយៗនៅក្នុងឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។<br>**ការពិភាក្សាពេញអង្គ(៣០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សួរសំណួរដូចខាងក្រោម៖<br>- តើជំហានណាខ្លះដែលលោក លោកស្រីអាចធ្វើបាន? | ច្បាប់រៀបចំអង្គការ មាត្រា៣៦ អនុក្រឹត្យ ២១៦ មាត្រា១៤, ៧០, ១៣២<br>គំរូបទបញ្ចាំងផ្ទៃក្នុង គោលបំណង និងកម្មវិធីតម្រង់ទិស ដែលសរសេរលើក្រដាសផ្ទាំងធំ |

| | | |
|---|---|---|
| | - តើជំហានណាខ្លះដែលលោក លោកស្រីត្រូវការគាំទ្របច្ចេកទេសបន្ថែម?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សរសេរចម្លើយរបស់សិក្ខាកាមលើក្រដាសផ្ទាំងធំ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ស្នើអោយសិក្ខាកាមកំណត់ប្រធានបទសម្រាប់ប្រឹក្សាយោបល់ដែលពួកគេត្រូវការជំនួយបច្ចេកទេសបន្ថែម។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ស្នើអោយសិក្ខាកាមព្រមព្រៀងលើប្រធានបទដែលត្រូវប្រឹក្សាយោបល់។<br><br>**ការបង្កើតកម្មវិធីសម្រាប់ការប្រឹក្សាយោបល់(៤៥នាទី)**<br>ក្រុមគោលដៅពិភាក្សា និងសម្រេចលើប្រធានបទសម្រាប់កម្មវិធីប្រឹក្សាយោបល់ស្តីអំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ | ផ្ទាំងរូបភាពទី ១<br>ទិដ្ឋភាពទូទៅនៃការរៀបចំកិច្ចប្រជុំ<br>ផ្ទាំងរូបភាពទី ២<br>ទិដ្ឋភាពទូទៅនៃការដំណើរការកិច្ចប្រជុំ<br><br>កម្មវិធីសម្រាប់ការប្រឹក្សាយោបល់ |
| **សង្ខេប និងសន្និដ្ឋាន (១៥នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សង្ខេបចំណុចសំខាន់ៗដែលបានរៀនសូត្រ និងបញ្ជាក់ពីកាលបរិច្ឆេទ សម្រាប់ការប្រឹក្សាយោបល់លើកក្រោយ។ | កម្មវិធីប្រឹក្សាយោបល់ដែលបានព្រមព្រៀង |

# កម្មវិធីសិក្ខាសាលាតម្រង់ទិសអំពីឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

| **ម៉ោង** | **ប្រធានបទ** | **អ្នកទទួលខុសត្រូវ** | **ផ្សេងៗ** |
|---|---|---|---|
| 08:00-08:15 | - មតិស្វាគមន៍ និងការណែនាំខ្លួន<br>- គោលបំណងនៃសិក្ខាសាលា | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ | |
| 08:15-08:30 | **សំណួរបំផុស**<br>- តើមានជំហានអ្វីខ្លះក្នុងការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា? | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ | |
| 08:30-09:30 | បទបង្ហាញទិដ្ឋភាពទូទៅនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ | |
| 09:30-09:45 | សំរាកអាហារសម្រន់ | | |
| 09:45-10:15 | **ការកំណត់ប្រធានបទ**<br>**ពិភាក្សាពេញអង្គ:**<br>- តើមានជំហានណាខ្លះដែលលោក លោកស្រីអាចធ្វើបាន?<br>- តើមានជំហានណាខ្លះដែលលោក លោកស្រីត្រូវការគាំទ្របច្ចេកទេសបន្ថែម? | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ | |
| 10:15-11:00 | រៀបចំកម្មវិធីសម្រាប់ការប្រឹក្សាយោបល់ | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ | |
| 11:00-11:15 | មតិបូកសរុប និងសន្និដ្ឋាន | តំណាងអ្នកចូលរួម | |
| 11:15-11:30 | បិទកម្មវិធី | ប្រធានក្រុមប្រឹក្សា | |

# ទិដ្ឋភាពទូទៅនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

## ផ្ទាំងរូបភាពទី១ ÷ ការត្រៀមរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា




### ជំហានទី១

**លទ្ធផល ÷** **នាយករដ្ឋបាលយល់ពីកិច្ចការរបស់ខ្លួនក្នុងការរៀបចំសេចក្តីព្រាងរបៀបវារៈ ហើយសមាជិកក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលបានយល់ពីសិទ្ធិរបស់ពួកគាត់ក្នុងការស្នើបញ្ហាដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា**

**វិធីសាស្ត្រ ÷**

- នាយករដ្ឋបាល រៀបចំសំណើបញ្ជីបញ្ហាតាមរយៈកិច្ចប្រជុំជាមួយប្រធានក្រុមប្រឹក្សា គណៈអភិបាល គណៈកម្មាធិការនានា ការពិនិត្យឡើងវិញនូវកំណត់ហេតុប្រជុំលើកមុន និងរបៀបវារៈដែលស្នើដោយសមាជិកក្រុមប្រឹក្សាចំនួន១ភាគ៣ (១/៣ ) ។

- សិទ្ធិរបស់សមាជិកក្រុមប្រឹក្សា ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងការដាក់បញ្ចូលបញ្ហាទៅក្នុងសេចក្តីព្រាងរបៀបវារៈ

  (ទម្រង់ទី១ក ១ខ ១គ និងទី២)

### ជំហានទី២

**លទ្ធផល ÷** **បញ្ហាណាខ្លះត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីព្រាងរបៀបវារៈ ឯកសារពាក់ព័ន្ធ អ្នកដែលត្រូវអញ្ជើញចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា**

**វិធីសាស្ត្រ ÷**

- នាយករដ្ឋបាល រៀបចំឯកសារពាក់ព័ន្ធកិច្ចប្រជុំក្រុមប្រឹក្សាដូចជាបញ្ជីបញ្ហាដែលបានស្នើឡើង របាយការណ៍របស់គណៈអភិបាល របាយការណ៍របស់គណៈកម្មាធិការនានា និងបញ្ជីឈ្មោះអ្នកចូលរួមដាក់ជូនប្រធានក្រុមប្រឹក្សា ។
- ប្រធានក្រុមប្រឹក្សា គណៈអភិបាល និងនាយករដ្ឋបាលជួបពិភាក្សាលើសេចក្តីព្រាងរបៀបវារៈ ហើយធានាថាបញ្ហាសំខាន់ៗត្រូវបានលើកឡើង ។
- ប្រធានក្រុមប្រឹក្សាធ្វើការសម្រេចចុងក្រោយលើសេចក្តីព្រាងរបៀបវារៈ បញ្ជីឯកសារពាក់ព័ន្ធ និងឈ្មោះអ្នកចូលរួម និងចុះហត្ថលេខាលើលិខិតអញ្ជើញ ។

( ទម្រង់ទី ៣ ៤ ៥ )

### ជំហានទី៣

**លទ្ធផល ÷** **ការចែកលិខិតអញ្ជើញ សេចក្តីព្រាងរបៀបវារៈ និងឯកសារផ្សេងៗដល់អ្នកពាក់ព័ន្ធនានា**

**វិធីសាស្ត្រ ÷**

- នាយករដ្ឋបាល ដោយមានជំនួយការពីទីចាត់ / ប្រធានការិយាល័យនានាត្រូវធានាថាសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន លិខិតអញ្ជើញ សេចក្តីព្រាងរបៀបវារៈនិងច្បាប់ចម្លងនៃឯកសារពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយដល់អ្នកចូលរួមយ៉ាងហោចណាស់ ៥ថ្ងៃការងារមុនកិច្ចប្រជុំចាប់ផ្តើម ។
- គណៈអភិបាល (ដែលមានអភិបាលរងមួយរូបទទួលបន្ទុកផ្នែកព័ត៌មាន) ត្រូវធានាថាព័ត៌មាននៃកិច្ចប្រជុំបានផ្សព្វផ្សាយទូលំទូលាយដល់សាធារណជនតាមរយៈក្តារព័ត៌មាន វិទ្យុ ទូរទស្សន៍ ឬ មធ្យោបាយផ្សេងទៀតជាដើម ។
- សមាជិកក្រុមប្រឹក្សាអាចជូនដំណឹងដល់អ្នកជិតខាង ឬ ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនឱ្យចូលរួមកិច្ចប្រជុំផងដែរ ។

## ផ្ទាំងរូបភាពទី២ ÷ដំណើរការកិច្ចប្រជុំក្រុមប្រឹក្សា

**ជំហានទី១**

**លទ្ធផល ÷ ការបើកកិច្ចប្រជុំ**

**វិធីសាស្ត្រ ÷ ប្រធានអង្គប្រជុំ**បើកកិច្ចប្រជុំ ហើយ**ត្រូវ**បញ្ជាក់ថា សមាជិកក្រុមប្រឹក្សានិងអ្នកពាក់ព័ន្ធនានាបានទទួលឯកសារទាំងអស់សម្រាប់កិច្ចប្រជុំជាមុនរួចហើយ ។

**ជំហានទី២**

**លទ្ធផល ÷ ការពិនិត្យកូរ៉ុម**

**វិធីសាស្ត្រ ÷ ប្រធានអង្គប្រជុំ**ដោយមានជំនួយពីនាយករដ្ឋបាលត្រូវធានាថាមានកូរ៉ុមគ្រប់គ្រាន់សម្រាប់ដំណើរការកិច្ចប្រជុំ ។ប្រសិនបើកូរ៉ុមមិនគ្រប់ទេ នោះត្រូវផ្អាកកិច្ចប្រជុំទៅពេលក្រោយ ។ (ទម្រង់ទី៦)

**ជំហានទី៣**

**លទ្ធផល ÷ ការអនុម័តសេចក្តីព្រាងរបៀបវារៈ**

**វិធីសាស្ត្រ ÷** ប្រធានអង្គប្រជុំត្រូវសម្របសម្រួលការពិភាក្សា និងការសម្រេចអនុម័តលើសំណើសុំកែប្រែសេចក្តីព្រាងរបៀបវារៈនីមួយៗ ។ **សមាជិកក្រុមប្រឹក្សា** មានសិទ្ធិស្នើដាក់បន្ថែម ឬកែប្រែប្រធានបទនៅក្នុងសេចក្តីព្រាងរបៀបវារៈ ។ (ទម្រង់ទី ៧)

**ជំហានទី៤**

**លទ្ធផល ÷ ការអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំលើកមុន**

**វិធីសាស្ត្រ ÷ប្រធានអង្គប្រជុំ** ត្រូវសម្របសម្រួលការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើសំណើសុំកែតម្រូវកំណត់ហេតុនៃកិច្ចប្រជុំលើកមុន ។

**សមាជិកក្រុមប្រឹក្សា**មានសិទ្ធិស្នើសុំកែតម្រូវកំណត់ហេតុនៃកិច្ចប្រជុំដោយយោងតាមខ្លឹមសារ និងការឯកភាពនៅក្នុងកិច្ចប្រជុំលើកមុន ។

**ជំហានទី៥**

**លទ្ធផល ÷ របាយការណ៍របស់គណៈអភិបាល និងគណៈកម្មាធិការនានា**

**វិធីសាស្ត្រ ÷ គណៈអភិបាល** និង**គណៈកម្មាធិការ**នានារាយការណ៍ពីការរីកចម្រើន ព្រមទាំងបញ្ហាប្រឈមក្នុងការអនុវត្តការងារសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា ។

**សមាជិកក្រុមប្រឹក្សា**មានសិទ្ធិសាកសួរសុំឱ្យស្រាយបំភ្លឺ ព្រមទាំងផ្តល់ការណែនាំតម្រង់ទិស ។




**ជំហានទី៦**

**លទ្ធផល ÷ ការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា**

**វិធីសាស្ត្រ ÷ សមាជិកក្រុមប្រឹក្សា**ធ្វើការពិភាក្សា និងសម្រេចលើបញ្ហានានា ដើម្បីការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាត្រូវអនុវត្តនូវអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនក្នុងការធ្វើសេចក្តីសម្រេច ។ ប្រធានក្រុមប្រឹក្សាសម្របសម្រួលនូវការពិភាក្សា និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ។ **(ទម្រង់ទី៨)**

**ជំហានទី៧**

**លទ្ធផល ÷ សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់**

**វិធីសាស្ត្រ ÷** ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងសង្គមស៊ីវិល ក្នុងការសួរសំណួរ បញ្ចេញមតិយោបល់ទៅលើបញ្ហាដែលបានពិភាក្សា និងសម្រេច ។

**ក្រុមប្រឹក្សា**អាចស្វែងយល់ពីតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងសង្គមស៊ីវិល ។

**ប្រធានក្រុមប្រឹក្សា**ជាអ្នកសម្របសម្រួលលើដំណើរការពិភាក្សា និងបញ្ចេញមតិយោបល់នេះ ។

**ជំហានទី៨**

**លទ្ធផល ÷ បញ្ហាផ្សេងៗ**

**វិធីសាស្ត្រ ÷**ជំហាននេះផ្តល់ឱកាសដល់សមាជិកក្រុមប្រឹក្សា អភិបាល គណៈអភិបាល ឬ នាយករដ្ឋបាលជូនដំណឹងនូវបញ្ហាផ្សេងៗ ។

**ប្រធានអង្គប្រជុំ** អញ្ជើញអ្នកមានបំណងចូលរួមជូនដំណឹងបន្ថែមឱ្យលើកដៃ ។

**ជំហានទី៩**

**លទ្ធផល ÷ ការបិទអង្គប្រជុំ**

**វិធីសាស្ត្រ ÷ប្រធានអង្គប្រជុំ**សង្ខេបពីសេចក្តីសម្រេចសំខាន់ៗនៃកិច្ចប្រជុំ ។

**ប្រធានអង្គប្រជុំ**ប្រកាសជូនពីកាលបរិច្ឆេទសម្រាប់កិច្ចប្រជុំលើកក្រោយ និងបិទអង្គប្រជុំ ។

ទម្រង់ទី១៖

# កម្មវិធីប្រឹក្សាយោបល់សម្រាប់កិច្ចប្រជុំបស់ក្រុមប្រឹក្សា

ខេត្តៈ..................................................

ក្រុង/ស្រុកៈ...........................................

| | ប្រធានបទដែលត្រូវប្រឹក្សាយោបល់ | ក្រុមគោលដៅ | កាលបរិច្ឆេទ | ពេលវេលា | ទីតាំង | កំណត់សំគាល់ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# ផ្នែកទី១៖ ការត្រៀមរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

## មេរៀនទី១ ៖ ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ

## (ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី១ និងទី២)

| ប្រធានបទ | ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ | សម្ភារៈ និង ឯកសារយោង |
|---|---|---|
| គោលបំណង | ▪ ក្រុមប្រឹក្សានឹងយល់អំពីសិទ្ធិរបស់ពួកគាត់ និងប្រភពធនធានផ្សេងៗទៀតសម្រាប់ប្រមូលបញ្ហាដើម្បីស្នើដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈ<br>▪ ក្រុមប្រឹក្សាអាចកំណត់ដំណោះស្រាយជាគន្លឹះសម្រាប់សំណើបញ្ហាដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈ | |
| ក្រុមគោលដៅ | សមាជិកក្រុមប្រឹក្សាទាំងអស់ | |
| រយៈពេល | ១ម៉ោង៣០នាទី | |
| ដំណើរការ<br>(១ម៉ោង) | **ការពិភាក្សាពេញអង្គ(១ម៉ោង១៥នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរនូវសំណួរដល់ក្រុមគោលដៅដូចខាងក្រោម (៤៥នាទី) ៖<br>• តើលោក លោកស្រី ធ្លាប់បានស្នើបញ្ហាសម្រាប់ដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងរបៀបវារៈដែរ ឬ ទេ?<br>  ▪ បើធ្លាប់ តើលោក លោកស្រីធ្វើដូចម្តេច?<br>  ▪ បើមិនធ្លាប់ តើមូលហេតុអ្វី?<br>• តើលោក លោកស្រីប្រមូលបញ្ហាទាំងនោះពីប្រភពណាខ្លះ?<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ជាមួយក្រុមគោលដៅថាពួកគាត់អាចប្រមូលបញ្ហាពីប្រភពផ្សេងៗទៀតបាន ។ បញ្ហាទាំងនោះមានដូចជា:<br>• របាយការណ៍ប្រចាំខែរបស់គណៈអភិបាល និងរបាយការណ៍របស់ប្រធានការិយាល័យហិរញ្ញវត្ថុស្តីអំពីស្ថានភាពហិរញ្ញវត្ថុ ។<br>• ព័ត៌មានអំពីក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល សារព័ត៌មាន ព្រឹត្តិប័ត្រផ្សេងៗ វិទ្យុ ទូរទស្សន៍ ហាងកាហ្វេ និងអ្នកជិតខាងផ្សេងៗ ។ល ។<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរដល់ក្រុមគោលដៅថា: | ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី១ សិទ្ធិក្រុមប្រឹក្សា និងប្រជាពលរដ្ឋ |

តើលោក លោកស្រីជួបការលំបាកអ្វីខ្លះក្នុងការស្នើបញ្ហាសម្រាប់ដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងរបៀបវារៈ? ហើយតើលោក លោកស្រីដោះស្រាយបញ្ហាលំបាកទាំងអស់នោះដោយរបៀបណា?(៣០នាទី)

មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើសុំក្រុមគោលដៅម្នាក់ស្ម័គ្រចិត្តក្នុងការកត់ត្រាចម្លើយអំពីឧបសគ្គនានា និងដំណោះស្រាយជាគន្លឹះដែលបានមកពីការពិភាក្សាពេញអង្គ។

មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ពិភាក្សាអំពីសិទ្ធិរបស់ក្រុមប្រឹក្សា និង សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការស្នើបញ្ហាដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈ (ក្រុមគោលដៅពិភាក្សាអំពីអ្វីដែលអាចធ្វើបានក្នុងការស្នើដាក់បញ្ចូលបញ្ហាទៅក្នុងសេចក្តីព្រាងរបៀបវារៈ)

- តើលោក លោកស្រី អាចធ្វើអ្វីបានខ្លះក្នុងការស្នើបញ្ហាដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងរបៀបវារៈ?

ស្នើសុំឱ្យក្រុមគោលដៅព្រមព្រៀងលើចំនួនថ្ងៃក្នុងការប្រមូលបញ្ហា និងព្រមព្រៀងលើសកម្មភាពដែលត្រូវធ្វើ។

**<u>សំណូមពរ:</u> មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់មិនគួរបញ្ជាក់នូវប្រយោគខាងក្រោមទេប្រសិនបើក្រុមគោលដៅយល់ព្រមដាក់សំណួរចម្លើយ និងការបញ្ចេញមតិយោបល់ទៅក្នុងសេចក្តីព្រាងរបៀបវារៈ។**

មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ពិភាក្សាជាមួយក្រុមគោលដៅអំពីសិទ្ធិរបស់ក្រុមប្រឹក្សាក្នុងការស្នើសុំដាក់បញ្ចូលនូវកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ទៅក្នុងសេចក្តីព្រាងរបៀបវារៈ ព្រមទាំងធ្វើការសង្ខេបអំពីសារៈសំខាន់នៃកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ និងបញ្ហាផ្សេងៗ ធ្វើដូចនេះពួកគាត់អាចមានជាគំនិតខ្លះៗដោយហេតុថាមេរៀននេះនឹងពិភាក្សាគ្នាលម្អិតនៅក្នុងមេរៀនទី៥ និងទី៧។

<u>**កំណត់សំគាល់**</u> សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ និងបញ្ហាផ្សេងៗមានសារៈសំខាន់ក្នុងការដាក់បញ្ចូលទៅសេចក្តីព្រាងរបៀបវារៈពីព្រោះ ៖

- **សំណួរ ចម្លើយ ការបញ្ចេញមតិយោបល់** គឺផ្តល់ ឱកាសដល់ប្រជាពលរដ្ឋ តំណាងអង្គការសង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីសួរសំណួរ

| | | |
|---|---|---|
| | និងផ្តល់យោបល់ត្រឡប់ភ្លាមៗអំពីបញ្ហាដែលបានពិភាក្សា និងសេចក្តីសម្រេច ក្នុងពេលប្រជុំក្រុមប្រឹក្សា វិធីសាស្ត្រនេះជាយន្តការមួយដើម្បីភ្ជាប់ទំនាក់ទំនង និងចូលរួមចំណែកធ្វើអោយក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះការសម្រេច ចិត្ត និងធានាថារាល់ការសម្រេចចិត្តទាំងនោះត្រូវបានអនុវត្ត ។<br>▪ **បញ្ហាផ្សេងៗ** គឺដើម្បីផ្តល់ឱកាសដល់ក្រុមប្រឹក្សាគណៈអភិបាល និងនាយករដ្ឋបាល ដើម្បីជូនដំណឹងអោយគ្នាទៅវិញទៅមកអំពីបញ្ហាផ្សេងៗដូចជា ៖ ទស្សនៈកិច្ចសិក្សា ផែនការអភិវឌ្ឍរបស់ម្ចាស់ជំនួយ ។ល ។ បញ្ហាទាំងអស់នោះមិនត្រូវយកមកជជែក នៅអំឡុងពេលប្រជុំក្រុមប្រឹក្សាទេ ។ | |
| **សង្ខេប និង សន្និដ្ឋាន** (១៥នាទី) | ក្រុមគោលដៅធ្វើការសង្ខេបចំណុចរៀនសូត្រសំខាន់ៗ ហើយមន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់នូវកម្មវិធីប្រឹក្សាយោបល់លើកក្រោយ ។ | កម្មវិធីប្រឹក្សាយោបល់ |

## មេរៀនទី២៖ ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ
## (ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី១ និងទី២)

| | | |
|---|---|---|
| **ប្រធានបទ** | ការកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ | **សម្ភារៈ និង ឯកសារយោង** |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះ<br>▪ ក្រុមគោលដៅអាចកំណត់បញ្ហាសម្រាប់រៀបចំសេចក្តីព្រាង របៀបវារៈដើម្បីពិភាក្សាក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា<br>▪ ក្រុមគោលដៅអាចកំណត់បានធនធានមនុស្ស ឯកសារពាក់ព័ន្ធ និងពេលវេលាសម្រាប់ដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈ | |
| **ក្រុមគោលដៅ** | ប្រធានក្រុមប្រឹក្សា គណៈអភិបាល និងនាយករដ្ឋបាល | |
| **រយៈពេល** | ៣ម៉ោង៣០នាទី | |
| **ដំណើរការ (៣ម៉ោង១០នាទី)** | **សំណួរបំផុស (១ម៉ោង)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរដូចខាងក្រោម:<br>▪ តើលោក លោកស្រីធ្វើដូចម្តេចដើម្បីកំណត់បញ្ហាសម្រាប់ដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈ?<br>▪ តើលោក លោកស្រីបានទទួលបានព័ត៌មានមកពីប្រភពណាខ្លះ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ និងបង្ហាញឯកសារបច្ចេសទេស ផ្នែកទី១ ជំហានទី១<br>ទម្រង់ទី១សម្រាប់ឱ្យប្រធានក្រុមប្រឹក្សាបញ្ជាក់លើទម្រង់នោះ។ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ទៅក្រុមគោលដៅថាទម្រង់ទី១នេះអាចកែតម្រូវបាន។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ជាមួយក្រុមគោលដៅថាពួកគាត់អាចប្រមូលបញ្ហាពីប្រភពផ្សេងៗទៀតបាន។ បញ្ហាទាំងនោះមានដូចជា:<br>▪ របាយការណ៍ប្រចាំខែរបស់គណៈអភិបាល និងរបាយការណ៍របស់ប្រធានការិយាល័យហិរញ្ញវត្ថុស្តីអំពីស្ថានភាពហិរញ្ញវត្ថុ<br>▪ កំណត់ហេតុប្រជុំលើកមុន<br>▪ **បញ្ហា**ដែលស្នើឡើងដោយសមាជិកក្រុមប្រឹក្សា១ភាគ៣ (១/៣) គណៈកម្មាធិការផ្សេងៗ មន្ទីរ ការិយាល័យជំនាញផ្សេងៗ និងតំណាងអង្គការសង្គមស៊ីវិល។ | ទម្រង់ទី១ (ក ខ និងគ)<br><br>ការព្រមព្រៀងទម្រង់ទី១ (ក ខ និងគ) |

| | | |
|---|---|---|
| | <u>**កំណត់សំគាល់ទី១**</u> មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ផ្តល់ពេលវេលាពី១ទៅ៣ថ្ងៃសម្រាប់ក្រុមគោលដៅក្នុងការប្រមូលនូវបញ្ហាពីប្រភពផ្សេងៗដូចដែលបានរៀបរាប់ខាងលើព្រមទាំងបំពេញទម្រង់ទី២(មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ផ្តល់ទម្រង់ទី២ដល់ក្រុមគោលដៅព្រមទាំងពន្យល់ពីរបៀបនៃការបំពេញ) ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ រំឭកដល់នាយករដ្ឋបាលឱ្យយកមកជាមួយនូវទម្រង់ទី២ ដែលបានបំពេញរួចសម្រាប់ការប្រឹក្សាយោបល់លើកក្រោយ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ត្រូវតាមដានត្រួតពិនិត្យជាមួយនាយករដ្ឋបាល ដើម្បីធានាថាទម្រង់ទី២ដែលបានបំពេញត្រឹមត្រូវមុនពេលប្រឹក្សាយោបល់លើកក្រោយ ។<br>**រយៈពេល: (១ម៉ោង)**<br>បន្ទាប់ពី១ទៅ៣ថ្ងៃមកមន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ និងក្រុមគោលដៅជួបគ្នាម្តងទៀត ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ត្រូវតែសំណេះសំណាលជាមួយក្រុមគោលដៅមុននឹងចាប់ផ្តើមមេរៀននេះ ។ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរទៅកាន់នាយករដ្ឋបាលនូវសំណួរដូចខាងក្រោម:<br>• តើលោក លោកស្រីយល់យ៉ាងដូចម្តេចដែរចំពោះទម្រង់ទី២នេះ?<br>• តើលោក លោកស្រីជួបផលលំបាកអ្វីដែរ ឬទេក្នុងការបំពេញទម្រង់នេះ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ជាមួយនាយករដ្ឋបាល និងក្រុមគោលដៅផ្សេងទៀតអំពីការបំពេញទម្រង់ទី២ ព្រមទាំង ទុកពេលអោយនាយករដ្ឋបាលធ្វើការកែតម្រូវទម្រង់ទី២ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ និងក្រុមគោលដៅពិភាក្សាអំពីឯកសារពាក់ព័ន្ធ និងភ្ញៀវដែលត្រូវអញ្ជើញចូលរួមដោយផ្អែកលើទម្រង់ទី២ ។<br>បន្ទាប់មកមន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បង្ហាញ និងពន្យល់ទម្រង់ទី៣ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើ ឱ្យនាយករដ្ឋបាលបំពេញទម្រង់ទី៣ដោយមានការចូលរួមយោបល់ពីប្រធានក្រុមប្រឹក្សា និងគណៈអភិបាល ។ (ទម្រង់ទី៣ឯកសារពាក់ព័ន្ធ និងភ្ញៀវត្រូវអញ្ជើញចូលរួម) ។<br>បន្ទាប់ពីមេរៀននេះ នាយករដ្ឋបាលផ្ញើទម្រង់ទី២ និងទម្រង់ទី៣ ដែលបានបំពេញរួចទៅប្រធានក្រុមប្រឹក្សាដើម្បីយល់ព្រមក្នុងការដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងរបៀបវារ | ទម្រង់ទី២ |

| | | |
|---|---|---|
| | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ រំលឹកដល់គណៈអភិបាលក្នុងការរៀបចំរបាយការណ៍ប្រចាំខែ ហើយផ្ញើទៅប្រធានក្រុមប្រឹក្សាយ៉ាងតិច៨ថ្ងៃនៃថ្ងៃធ្វើការមុនកិច្ចប្រជុំចាប់ផ្តើម ។<br>បន្ទាប់មកគណៈអភិបាលជួបជាមួយប្រធានក្រុមប្រឹក្សាដើម្បីពិភាក្សាប្រសិនបើមានអ្វីត្រូវកែតម្រូវ ។<br><br>**<u>កំណត់សំគាល់ទី២ ៖</u>**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ជួបជាមួយប្រធានក្រុមប្រឹក្សាដើម្បីព្រមព្រៀងជាចុងក្រោយលើទម្រង់ទី២ និងទី៣ ក្នុងពេលវេលាសមស្របមួយ ។<br>ក្នុងករណីប្រធានក្រុមប្រឹក្សាអាចពិនិត្យជាចុងក្រោយលើទម្រង់ទី២និង៣ ក្នុងអំឡុងពេលប្រឹក្សាយោបល់មេរៀននេះ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ ត្រូវបន្តអនុវត្តនូវជំហានបន្ទាប់ ។<br><br>ក្នុងករណីដែលទម្រង់ទី២ (សេចក្តីព្រាងបញ្ហាសម្រាប់ដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈ) និងទម្រង់ទី៣ (បញ្ជីឯកសារពាក់ព័ន្ធ និងឈ្មោះអ្នកដែលត្រូវអញ្ជើញចូលរួម) មិនទាន់បានបំពេញចប់សព្វគ្រប់ដោយនាយករដ្ឋបាល មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ គួរ ទុកពេលវេលាឱ្យនាយករដ្ឋបាល គណៈអភិបាល និងប្រធានក្រុមប្រឹក្សាពិភាក្សា និងបំពេញទម្រង់ទាំងនោះ ។ | ទម្រង់ទី៣ បានបំពេញ ចុងក្រោយ |
| | **រយៈពេល (១ម៉ោង១០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សួរក្រុមគោលដៅថាតើពួកគាត់មានទម្រង់សេចក្តីព្រាងរបៀបវារៈដែរឬទេ? ប្រសិនបើមាន មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ពិភាក្សាជាមួយក្រុមគោលដៅលើទម្រង់នោះតែម្តង ។ ប្រសិនបើពួកគាត់មិនមានទម្រង់នោះទេ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បង្ហាញទៅក្រុមគោលដៅនូវទម្រង់ទី៤ នៃសេចក្តីព្រាងរបៀបវារៈ ។<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើអោយក្រុមគោលដៅជ្រើសរើសបញ្ហាសំខាន់ៗ ដែលបានព្រមព្រៀងជាមួយប្រធានក្រុមប្រឹក្សាពីទម្រង់ទី ៣ដាក់ក្នុងទម្រង់ទី៤ នៃសេចក្តីព្រាងរបៀបវារៈ ព្រមទាំងចាត់ចែងពេលវេលា និងកំណត់ធនធានមនុស្សសម្រាប់សេចក្តីព្រាងរបៀបវារៈនីមួយៗដូចជា: | ទម្រង់ទី៤ |

| | | |
|---|---|---|
| | ១. បើកកិច្ចប្រជុំ (xxនាទី)<br>២. ការពិនិត្យកូរ៉ុម (xxនាទី)<br>៣. ពិនិត្យនិងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ (xxនាទី)<br>៤. ការអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំលើកមុន (xxនាទី)<br>៥. ពិភាក្សា ផ្តល់យោបល់ សំណួរ និងចម្លើយ (xxនាទី)<br>ប្រសិនបើចាំបាច់មន្រ្តីសម្របសម្រួល និងប្រឹក្សាយោបល់ អាចបង្ហាញសេចក្តីព្រាងរបៀបវារៈគំរូដល់ក្រុមគោលដៅដូចខាងក្រោមៈ<br>• បើកកិច្ចប្រជុំ<br>• ការពិនិត្យកូរ៉ុម<br>• ពិនិត្យនិងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ<br>• ការអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំលើកមុន<br>• របាយការណ៍របស់គណៈអភិបាល<br>• ការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នាពេលខាងមុខ<br>• សេចក្តីព្រាងដីកាដើម្បីហាមឃាត់ការបង្កសម្លេងផ្សេងៗលាន់ឮខ្លាំងៗនៅក្រោយម៉ោង១១យប់<br>• បញ្ហាផ្សេងៗ<br>• សំណួរម្លើយនិងការបញ្ចេញមតិយោបល់ពីសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា<br>• ជូនព័ត៌មានពីកាលបរិច្ឆេទនិងទីកន្លែងជាក់លាក់នៃកិច្ចប្រជុំលើកក្រោយ<br>• ការបិទកិច្ចប្រជុំ<br><br>មន្រ្តីសម្របសម្រួល និងប្រឹក្សាយោបល់ បញ្ជាក់ជាមួយក្រុមគោលដៅអំពីការផ្ញើលិខិតអញ្ជើញ (ទម្រង់ទី៥) និង ឯកសារពាក់ព័ន្ធទៅភ្ញៀវ ដែលត្រូវអញ្ជើញទាំងអស់យ៉ាងតិច៥ថ្ងៃនៃថ្ងៃធ្វើការមុនកិច្ចប្រជុំចាប់ផ្តើម។<br>**<u>កំណត់សំគាល់ទី៣</u> ៖** មន្រ្តីសម្របសម្រួល និងប្រឹក្សាយោបល់គួរតែបញ្ជាក់ជាមួយក្រុមគោលដៅថាទម្រង់ទាំងអស់នេះអាចធ្វើការកែប្រែបាន។ | ទម្រង់ទី៥ |
| **សង្ខេប និងសន្និដ្ឋាន (២០នាទី)** | មន្រ្តីសម្របសម្រួល និងប្រឹក្សាយោបល់ សង្ខេបចំណុច ដែលត្រូវរៀនសូត្រ សំខាន់ៗ និង (សូមមើលដ្យាក្រាមនៃការប្រើប្រាស់ទម្រង់ខាងក្រោម)ហើយ មន្រ្តីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ពីកម្មវិធីដែលត្រូវប្រឹក្សាយោបល់លើកក្រោយ | កម្មវិធីប្រឹក្សាយោបល់ |

# ដ្យាក្រាមនៃការប្រើប្រាស់ទម្រង់

**ទម្រង់ទី១**

**ទម្រង់១ ក**

សម្រាប់ក្រុមប្រឹក្សាម្នាក់ៗ

**ទម្រង់១ ខ**

សម្រាប់ក្រុមប្រឹក្សាជាក្រុម

**ទម្រង់១ គ**

អ្នកដទៃមិនមែនក្រុមប្រឹក្សា

បន្ទាប់ពីបញ្ជាក់ដោយ
ប្រធានក្រុមប្រឹក្សាហើយ
ផ្ញើទៅនាយករដ្ឋបាល១០
ថ្ងៃមុនកិច្ចប្រជុំ

**ទម្រង់ទី២**

បញ្ជីបញ្ហាសម្រាប់ដាក់ក្នុង
សេចក្តីព្រាងរបៀបវារៈ

បំពេញដោយនាយករដ្ឋបាល ៨ថ្ងៃមុន
កិច្ចប្រជុំចាប់ផ្តើម

**ទម្រង់ទី៣** បញ្ជីឯកសារពាក់ព័ន្ធ
និង ឈ្មោះអ្នកចូលរួមកិច្ចប្រជុំ

បំពេញដោយនាយករដ្ឋបាល
៨ថ្ងៃ មុនកិច្ចប្រជុំចាប់ផ្តើម

**ទម្រង់ទី៤** សេចក្តីព្រាងរបៀបវារៈ
នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

បំពេញដោយនាយករដ្ឋបាល ៨ថ្ងៃ
មុនកិច្ចប្រជុំចាប់ផ្តើម

**ទម្រង់ទី៥** លិខិតអញ្ជើញ

បំពេញដោយនាយករដ្ឋបាល ៥ថ្ងៃមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាចាប់ផ្តើម



**មេរៀនទី៣៖ ការផ្ញើលិខិតអញ្ជើញ និងផ្សព្វផ្សាយសេចក្តីព្រាងរបៀបវារៈ និងឯកសារពាក់ព័ន្ធនានា**

**(ឯកសារបច្ចេកទេស ផ្នែកទី១ ជំហានទី៣)**

| **ប្រធានបទ** | ការផ្ញើជូនលិខិតអញ្ជើញ និងការផ្សព្វផ្សាយសេចក្តីព្រាងរបៀបវារៈ និងឯកសារពាក់ព័ន្ធនានា | **សម្ភារៈ និងឯកសារយោង** |
|---|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះក្រុមគោលដៅយល់ដឹងអំពីសារៈសំខាន់នៃការផ្ញើជូនលិខិតអញ្ជើញ និងការផ្សព្វផ្សាយសេចក្តីព្រាងរបៀបវារៈ និងឯកសារពាក់ព័ន្ធនានាជូនអ្នកដែលពាក់ព័ន្ធឱ្យបានមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាចាប់ផ្តើម | |
| **ក្រុមគោលដៅ** | ប្រធានក្រុមប្រឹក្សា អភិបាលរង (ទទួលបន្ទុកផ្នែកផ្សព្វផ្សាយព័ត៌មាន) និងនាយករដ្ឋបាល | |
| **រយៈពេល** | ១ម៉ោង១៥នាទី | |
| **ដំណើរការ (១ម៉ោង)** | **សំណួរបំផុស (១ម៉ោង)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរដូចខាងក្រោម:<br>• តើមានសារៈសំខាន់អ្វីខ្លះក្នុងការផ្ញើលិខិតអញ្ជើញ និងការផ្សព្វផ្សាយសេចក្តីព្រាងរបៀបវារៈ និងឯកសារពាក់ព័ន្ធនានាជូនអ្នកពាក់ព័ន្ធឱ្យបានមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាចាប់ផ្តើម?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរបន្ត:<br>• តាមបទពិសោធន៍ តើលោក លោកស្រីផ្ញើលិខិតអញ្ជើញ និងឯកសារពាក់ព័ន្ធនានាប៉ុន្មានថ្ងៃមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាចាប់ផ្តើមជូនអ្នកចូលរួម និងអ្នកពាក់ព័ន្ធ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរបន្តទៀត:<br>• តើលោក លោកស្រីធ្វើដូចម្តេចដើម្បីផ្ញើលិខិតអញ្ជើញ និងឯកសារពាក់ព័ន្ធនានាជូនអ្នកពាក់ព័ន្ធ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បង្ហាញវិធីសាស្ត្រសមស្របក្នុងការផ្សព្វផ្សាយព័ត៌មានហើយវិធីនេះក៏មានក្នុងឯកសារបច្ចេកទេសផ្នែកទី១ ជំហានទី៣ដូចខាងក្រោម:<br>• ក្តារព័ត៌មានសាធារណៈ | ឯកសារបច្ចេកទេសផ្នែកទី១ ជំហានទី៣ |

| | | |
|---|---|---|
| | • ក្តារព័ត៌មានឃុំ សង្កាត់<br>• សារព័ត៌មានមូលដ្ឋានដូចជា (វិទ្យុ កាសែត ។ល។)<br>• អង្គការសង្គមស៊ីវិលមូលដ្ឋាន<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ថាក្រៅពីឯកសារបច្ចេកទេស ផ្នែកទី១ជំហានទី៣ គឺមានវិធីសាស្ត្រសមស្របផ្សេងទៀតក្នុងការផ្សព្វផ្សាយព័ត៌មានដូចជាពិធីបុណ្យផ្សេងៗតាមទីសាធារណៈ ។ល។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ និងក្រុមគោលដៅព្រមព្រៀងទៅលើវិធីសាស្ត្រសមស្រប និងពេលវេលាសម្រាប់ផ្ញើជូនអ្នកចូលរួម និងផ្សព្វផ្សាយ ។ | |
| **សង្ខេប និង សន្និដ្ឋាន (១៥នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សង្ខេបចំណុចត្រូវរៀនសូត្រសំខាន់ៗ និងបញ្ជាក់ពីកម្មវិធីដែលត្រូវប្រឹក្សាយោបល់លើកក្រោយ ។ | កម្មវិធីប្រឹក្សាយោបល់ |

# ផ្នែកទី២៖ ដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

## មេរៀនទី១ ÷ ការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន

## (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៣ និងទី៤)

| ប្រធានបទ | ការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន | សម្ភារៈ និងឯកសារយោង |
|---|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀននេះ ក្រុមគោលដៅអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការស្នើសុំកែប្រែសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន | |
| ក្រុមគោលដៅ | សមាជិកក្រុមប្រឹក្សាទាំងមូល | |
| រយៈពេល | ១ម៉ោង | |
| ដំណើរការ (៤៥នាទី) | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ថា តាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា ត្រូវអនុម័តសេចក្តីព្រាងរបៀបវារៈ កំណត់ហេតុកិច្ចប្រជុំលើកមុន។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរខាងក្រោម ៖<br>• តាមបទពិសោធន៍លោកអ្នកបានធ្វើអ្វីខ្លះនៅក្នុងដំណើរការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុកិច្ចប្រជុំលើកមុន?<br>• តើក្រុមប្រឹក្សាម្នាក់ៗមានសិទ្ធិអ្វីខ្លះក្នុងដំណើរការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុកិច្ចប្រជុំលើកមុន?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ ដោយចែកចេញជាពីរផ្នែកៈ ផ្នែកទី១ ៖ ការអនុម័តរបៀបវារៈ និងផ្នែកទី២ ៖ អនុម័តកំណត់ហេតុកិច្ចប្រជុំលើកមុន។<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ផ្ទះបញ្ចាំងជាមួយក្រុមគោលដៅនូវចម្លើយ ស្តីពីសិទ្ធិរបស់ពួកគាត់ បញ្ហាប្រឈម និងដំណោះស្រាយហើយអានឯកសារបច្ចេកទេស ជំហានទី៣ និង៤ (ផ្នែកទី២ សិទ្ធិរបស់ក្រុមប្រឹក្សា និងដំណើរការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុកិច្ចប្រជុំលើកមុន) ។<br><u>**កំណត់សំគាល់**</u> ៖ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់គួរផ្តោតទៅលើសិទ្ធិរបស់ក្រុមប្រឹក្សា ដែលមានចែងនៅក្នុងឯកសារបច្ចេកទេសជាជាងបញ្ហាប្រឈម និងដំណោះស្រាយ ។ | ឯកសារបច្ចេកទេស ជំហានទី៣ និងទី៤ (ផ្នែកទី២) |
| សង្ខេប និងសន្និដ្ឋាន (១៥នាទី) | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចត្រូវរៀនសូត្រសំខាន់ៗ និងបញ្ជាក់ពីកម្មវិធី ដែលត្រូវប្រឹក្សាយោបល់លើកក្រោយជាមួយប្រធានក្រុមប្រឹក្សា។ | កម្មវិធីប្រឹក្សាយោបល់ |

## មេរៀនទី២៖ តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន
## (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៣ និងទី៤)

| | | |
|---|---|---|
| **ប្រធានបទ** | តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន | **សម្ភារៈ និង ឯកសារយោង** |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះ ប្រធានក្រុមប្រឹក្សាអាចសម្របសម្រួលដំណើរការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុនកាន់តែប្រសើរ | |
| **ក្រុមគោលដៅ** | ប្រធានក្រុមប្រឹក្សា | |
| **រយៈពេល** | ១ម៉ោង១៥នាទី | |
| **ដំណើរការ (១ម៉ោង)** | **សំណួរបំផុស (៤០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរដល់ប្រធានក្រុមប្រឹក្សា៖<br>• តើលោកអ្នកមានតួនាទីអ្វីខ្លះក្នុងការសម្របសម្រួលដំណើរការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយទាំងអស់នៅលើក្រដាសផ្ទាំងធំ និងពិភាក្សា ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់រំឭកពីតួនាទីរបស់ប្រធានក្រុមប្រឹក្សានៅក្នុងឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៣ និងទី៤ ។<br>**ការពិភាក្សាពេញអង្គ(២០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរប្រធានក្រុមប្រឹក្សា៖<br>• តើអ្នកណាអាចជួយគាំទ្រលោក លោកស្រីក្នុងការសម្របសម្រួលដំណើរការអនុម័តសេចក្តីព្រាងរបៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន ?<br>• តើលោក លោកស្រីគិតថាគាត់គួរមានតួនាទីអ្វីខ្លះក្នុងការជួយសម្របសម្រួល?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយទាំងអស់នៅលើក្រដាសផ្ទាំងធំ និងបញ្ជាក់ពីអ្នក ដែលមានតួនាទីក្នុងការជួយប្រធានក្រុមប្រឹក្សាដោយយោងទៅលើឯកសារបច្ចេកទេសផ្នែកទី២ ជំហានទី៣ និងទី៤ ។ | ឯកសារ បច្ចេកទេស ផ្នែកទី២ ជំហានទី៣ និងទី៤ |
| **សង្ខេប និង សន្និដ្ឋាន (១៥នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចត្រូវរៀនសូត្រសំខាន់ៗ និងបញ្ជាក់ពីកម្មវិធីដែលត្រូវប្រឹក្សាយោបល់លើកក្រោយជាមួយប្រធានក្រុមប្រឹក្សា។ | កម្មវិធីប្រឹក្សាយោបល់ |

**មេរៀនទី៣ ៖ ការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្ត (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៦)**

| ប្រធានបទ | ការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា | សម្ភារៈ និង ឯកសារយោង |
|---|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀននេះ ក្រុមគោលដៅយល់ដឹងកាន់តែប្រសើរអំពីដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា | |
| ក្រុមគោលដៅ | សមាជិកក្រុមប្រឹក្សាទាំងមូល | |
| រយៈពេល | ២ម៉ោង | |
| ដំណើរការ (១ម៉ោង ៤៥នាទី) | **សេចក្តីផ្តើម (១០នាទី)**<br>យោងទៅលើបទបញ្ជាផ្ទៃក្នុង ប្រការ៩ តម្រូវឱ្យក្រុមប្រឹក្សាដាក់បញ្ចូលនូវកម្មវិធីពិភាក្សា និងការធ្វើសេចក្តីសម្រេចទៅក្នុងសេចក្តីព្រាងរបៀបវារៈ ។<br><br>**សំណួរបំផុស (២៥នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរខាងក្រោមៈ<br>• តាមបទពិសោធន៍ តើលោក លោកស្រីធ្វើយ៉ាងដូចម្តេចក្នុងដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានាក្នុងកិច្ចក្រជុំរបស់ក្រុមប្រឹក្សា?<br>• តើលោក លោកស្រីជួបផលលំបាកអ្វីខ្លះក្នុងដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា?<br>• តើលោក លោកស្រីបានដោះស្រាយបញ្ហាទាំងនោះដោយរបៀបណា?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយទាំងអស់នៅលើក្រដាសផ្ទាំងធំ ហើយអ្នកសម្របសម្រួល និងប្រឹក្សាយោបល់បង្ហាញពីចំណុចគួរពិចារណារនៅក្នុងដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចដោយយោងទៅលើឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៦ ។<br>**ការសម្តែងតួ (៥០នាទី)**<br>**(សំណូមពរៈ ប្រសិនបើក្រុមគោលដៅយល់ព្រមសំដែងតួ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ត្រូវសម្របសម្រួលដំណើរការនេះ)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើសុំអោយក្រុមគោលដៅជ្រើសរើសប្រធានបទពីកិច្ចប្រជុំលើកមុនដើម្បីសម្តែងតួ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ជ្រើសរើសអ្នកសម្តែង៨នាក់ (ប្រធានក្រុមប្រឹក្សា១នាក់ សមាជិកក្រុមប្រឹក្សា២នាក់ តំណាងគណៈកម្មាធិការផ្សេងៗ | បទបញ្ជាផ្ទៃក្នុង ប្រការ៩<br><br>ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៦ |

| | | |
|---|---|---|
| | ២នាក់ គណៈអភិបាល២នាក់ និងនាយករដ្ឋបាល១នាក់) និងអ្នកដែលនៅសល់ជាអ្នកសង្កេតការណ៍។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើសុំអោយក្រុមគោលដៅអនុវត្តតាមឯកសារបច្ចេកទេសផ្នែកទី២ ជំហានទី៦ ។<br>**<u>កំណត់សំគាល់</u>** ៖ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើសុំអោយក្រុមគោលដៅបង្ហាញប្រធានបទដែលត្រូវធ្វើការពិភាក្សាដោយៈ<br>• ពន្យល់ពីបញ្ហាដែលត្រូវលើកឡើង<br>• បង្ហាញពីឯកសារពាក់ព័ន្ធទៅនឹងបញ្ហានោះ<br>• ពន្យល់នូវអ្វីដែលចាំបាច់ត្រូវធ្វើពាក់ព័ន្ធទៅនឹងបញ្ហាទាំងនោះ។<br><br>**ការឆ្លុះបញ្ចាំង និងយោបល់ត្រឡប់(២០នាទី)**<br>បន្ទាប់ពីការសម្តែងតួ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើសុំអោយក្រុមគោលដៅ (អ្នកសម្តែង និងអ្នកសង្កេតការណ៍) ឆ្លុះបញ្ចាំង និងផ្តល់យោបល់ត្រឡប់ដោយឆ្លើយនឹងសំណួរខាងក្រោម ៖<br>• តើអ្វីខ្លះដែលធ្វើបានល្អ ?<br>• តើអ្វីខ្លះដែលត្រូវការកែលម្អ ?<br>• សូមអោយតួសម្តែងបញ្ចេញចំណាប់អារម្មណ៍<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សំយោគលទ្ធផលពីអ្នកសង្កេតការណ៍។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើឲ្យក្រុមគោលដៅព្រមព្រៀងលើសកម្មភាពដែលត្រូវអនុវត្ត ហើយមន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់នឹងចូលរួមសង្កេតការណ៍នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាលើកក្រោយ។ | |
| **សង្ខេប និង សន្និដ្ឋាន (១៥នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចនានាដែលត្រូវរៀនសូត្រស្តីអំពីការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្ត និងបញ្ជាក់ពីកម្មវិធីប្រឹក្សាយោបល់លើកក្រោយ។ | កម្មវិធីប្រឹក្សាយោបល់ |

## មេរៀនទី៤៖ តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា
## (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៦)

| | | |
|---|---|---|
| **ប្រធានបទ** | តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងដំណើរការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា | **សម្ភារៈ និង ឯកសារយោង** |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះ ប្រធានក្រុមប្រឹក្សានឹងអាចកំណត់បាននូវតួនាទីបន្ថែមដែលគាត់គួរធ្វើក្នុងដំណើរការពិភាក្សានិងការធ្វើសេចក្តីសម្រេចលើបញ្ហានានា | |
| **ក្រុមគោលដៅ** | ប្រធានក្រុមប្រឹក្សា | |
| **រយៈពេល** | ៤០នាទី | |
| **ដំណើរការ (៣០នាទី)** | <u>**កំណត់សំគាល់:**</u> មេរៀននេះគួរតែធ្វើឡើងបន្ទាប់ពីមេរៀនទី៣<br>**ការពិភាក្សាពេញអង្គ(៣០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ស្នើឱ្យប្រធានក្រុមប្រឹក្សាចែករំលែកគំនិតយោបល់ស្តីពីដំណើរការសម្របសម្រួលការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើកមុន និងការសម្តែងតួនៅក្នុងមេរៀនទី៣ ។<br>(បើសិនជាការសំដែងតួមិនអាចធ្វើបាន នៅក្នុងមេរៀនទី៣សូមរំលងចំណុចនេះ)<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរប្រធានក្រុមប្រឹក្សាៈ តើលោកលោកស្រីមានផ្នែកណាខ្លះ ដែលមិនទាន់ពេញចិត្តហើយចង់កែលម្អ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ និងប្រធានក្រុមប្រឹក្សាព្រមព្រៀងលើកិច្ចការដែលត្រូវប្រឹក្សាយោបល់អំពីការពិភាក្សា និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើចម្លើយដែលបានកត់ត្រាលើក្រដាសផ្ទាំងធំ ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់នឹងចូលរួមសង្កេតការណ៍នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាលើកក្រោយ ។ | |
| **សង្ខេប និង សន្និដ្ឋាន (១០នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចរៀនសូត្រសំខាន់ៗស្តីពីដំណើរការសម្របសម្រួលការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា និងបញ្ជាក់ពីកម្មវិធីប្រឹក្សាយោបល់លើកក្រោយ ។ | កម្មវិធីប្រឹក្សាយោបល់ |

## មេរៀនទី៥÷ សំណួរចម្លើយ និងការបញ្ចេញមតិយោបល់ (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៧)

| **ប្រធានបទ** | សំណួរ-ចម្លើយ និងការបញ្ចេញមតិយោបល់ | **សម្ភារៈ និង ឯកសារយោង** |
|---|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះ សមាជិកក្រុមប្រឹក្សាទាំងអស់យល់ដឹងកាន់តែប្រសើរ អំពីសារៈសំខាន់នៃសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ | |
| **ក្រុមគោលដៅ** | សមាជិកក្រុមប្រឹក្សាទាំងមូល | |
| **រយៈពេល** | ៤០នាទី | |
| **ដំណើរការ (៣០នាទី)** | **សំណួរបំផុស (៣០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរក្រុមគោលដៅ ៖<br>• ហេតុអ្វីបានជាក្រុមប្រឹក្សាត្រូវដាក់បញ្ចូលកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ក្នុងសេចក្តីព្រាងរបៀបវារៈ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ និងបញ្ជាក់បន្ថែមជាមួយក្រុមគោលដៅនូវចំណុចខាងក្រោម ៖<br>• **កម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់** ជាការផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ តំណាងសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការសួរសំណួរ និងផ្តល់យោបល់ត្រឡប់ភ្លាមៗទៅលើបញ្ហាដែលបានពិភាក្សា និងសម្រេចនៅក្នុងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។<br>• **កម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់** ជាយន្តការនៃការចូលរួមដែលនាំឱ្យមានគណនេយ្យភាពលើសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចនោះ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរក្រុមគោលដៅ:<br>• តើលោក លោកស្រីធ្វើដូចម្តេចដើម្បីផ្សព្វផ្សាយកម្មវិធីសំណួរ-ចម្លើយ និងការបញ្ចេញមតិយោបល់នេះទៅដល់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ សង្កាត់?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ បញ្ជាក់ថាសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់នេះ អាចផ្សព្វផ្សាយដល់ ប្រជាពលរដ្ឋ តំណាងសង្គមស៊ីវិល និង | សេចក្តីព្រាងរបៀបវារៈ<br><br>ឯកសារបច្ចេកទេសពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (ផ្នែកទី២ ជំហានទី៧) |

| | | |
|---|---|---|
| | ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈ<br>• ក្ដារព័ត៌មាន<br>• កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់<br>• កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក<br>• វេទិកាសាធារណៈ<br>• កិច្ចប្រជុំប្រឹក្សាយោបល់<br>• អ្នកជិតខាងរបស់ក្រុមប្រឹក្សា... ។ល ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់និងក្រុមគោលដៅព្រមព្រៀងលើសកម្មភាពដែលត្រូវអនុវត្តន្ត។ | |
| **សង្ខេប និង សន្និដ្ឋាន (១០នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ សង្ខេបចំនុចរៀនសូត្រសំខាន់ៗ និងបញ្ជាក់ពីកម្មវិធីសម្រាប់ការប្រឹក្សាយោបល់លើកក្រោយ ។ | កម្មវិធីប្រឹក្សាយោបល់ |

## មេរៀនទី៦៖ សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ (ឯកសារបច្ចេកទេស ផ្នែកទី២ ជំហានទី៧)

| **ប្រធានបទ** | សំណួរ-ចម្លើយនិងការបញ្ចេញមតិយោបល់ | **សម្ភារៈ និង ឯកសារយោង** |
|---|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះប្រធានក្រុមប្រឹក្សា និងនាយករដ្ឋបាលមានការយល់ដឹងកាន់តែប្រសើរក្នុងដំណើរការសម្របសម្រួលកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់។ | |
| **ក្រុមគោលដៅ** | ប្រធានក្រុមប្រឹក្សា និងនាយករដ្ឋបាល | |
| **រយៈពេល** | ១ម៉ោង | |
| **ដំណើរការ (៥០នាទី)** | **សេចក្តីផ្តើម(១០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរក្រុមគោលដៅ:<br>ហេតុអ្វីបានជាកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់មានសារៈសំខាន់?<br>ក្រុមគោលដៅចែករំលែកការយល់ដឹង។<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បង្ហាញនូវចំណុចដូចខាងក្រោម ៖<br>• សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ គឺមិនតម្រូវដោយច្បាប់ទេ តែក្រុមប្រឹក្សាអាចជ្រើសរើសដើម្បីដាក់បញ្ចូលក្នុងសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។<br>• សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ ជាការផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ តំណាងសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការសួរសំណួរ និងផ្តល់យោបល់ត្រឡប់ភ្លាមៗទៅលើបញ្ហាដែលបានពិភាក្សា និងសម្រេចនៅក្នុងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។<br>• សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ ជាយន្តការនៃការចូលរួមដែលនាំឱ្យមានគណនេយ្យភាពលើសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចនោះ។<br><br>**សំណួរបំផុស (៤០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរក្រុមគោលដៅនូវសំណួរខាងក្រោម:<br>• តើលោក លោកស្រីដំណើរការកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់យ៉ាងដូចម្តេច?<br>• តើលោក លោកស្រី ធ្វើដូចម្តេចដើម្បីលើកទឹកចិត្តដល់ប្រជាពលរដ្ឋ | ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (ផ្នែកទី២ ជំហានទី៧)<br><br>សេចក្តីព្រាងរបៀបវារៈ (ផ្នែកទី២ ជំហានទី៧) |

| | | |
|---|---|---|
| | សង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យលើកបញ្ហានានារបស់ពួកគេក្នុងកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់? <br><br> មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ហើយ ឱ្យក្រុមគោលដៅអាន និងពិភាក្សាលើដំណើរការកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ ក្នុងឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (ផ្នែកទី២ ជំហានទី៧) ដោយយកចិត្តទុកដាក់លើតួនាទី និងការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សា និងនាយករដ្ឋបាល ។ <br><br> មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរក្រុមគោលដៅថា: ក្រៅពីចំនុចដែលបានលើកឡើងនៅក្នុងឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សា តើមានសកម្មភាពអ្វីផ្សេងទៀតដែលលោក លោកស្រីអាចធ្វើបានដើម្បីសម្របសម្រួលដំណើរការកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់? <br> មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់និងក្រុមគោលដៅព្រមព្រៀងលើសកម្មភាពដែលត្រូវអនុវត្តបន្ត។ | |
| **សង្ខេប និង សន្និដ្ឋាន (១០នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចរៀនសូត្រសំខាន់ៗ និងបញ្ជាក់ពីកម្មវិធីសម្រាប់ការប្រឹក្សាយោបល់លើកក្រោយ ។ | កម្មវិធីប្រឹក្សាយោបល់ |

**មេរៀនទី៧ ៖ បញ្ហាផ្សេងៗ (ផ្នែកទី២ ជំហានទី៨)**

| ប្រធានបទ | បញ្ហាផ្សេងៗ | សម្ភារៈ និង ឯកសារយោង |
|---|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះក្រុមគោលដៅមានការយល់ដឹងជារួមលើមេរៀនស្តីពីបញ្ហាផ្សេងៗ និងភាពខុសគ្នារវាងបញ្ហាផ្សេងៗទៅនឹងកម្មវិធី សំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ | |
| **ក្រុមគោលដៅ** | ប្រធានក្រុមប្រឹក្សា និងនាយករដ្ឋបាល | |
| **រយៈពេល** | ១ម៉ោង | |
| **ដំណើរការ (៥០នាទី)** | **សំណួរបំផុស (១០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរក្រុមគោលដៅនូវសំណួរខាងក្រោម:<br>• តាមការយល់ឃើញរបស់អ្នក តើបញ្ហាអ្វីខ្លះដែលនឹងត្រូវយកមកជម្រាបជូនក្នុងជំហាននេះ ? (ឯកសារបច្ចេកទេសផ្នែកទី២ ជំហានទី៨)<br>• តើមានភាពខុសគ្នាអ្វីខ្លះរវាងកម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ និងបញ្ហាផ្សេងៗ ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br><br>**ការពិភាក្សាពេញអង្គ (៤០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់អោយក្រុមគោលដៅអានឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សា(ផ្នែកទី២ ជំហានទី៨)<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ពីភាពខុសគ្នារវាងសំណួរ ចម្លើយ និងការបញ្ចេញមតិ យោបល់ និងបញ្ហាផ្សេងៗ ដោយបរិយាយលំអិតនូវឃ្លាខាងក្រោម ៖<br>• បញ្ហាផ្សេងៗ គឺជាការផ្តល់ឱកាសដល់ក្រុមប្រឹក្សាទាំងមូល គណៈអភិបាល អភិបាល ឬ នាយករដ្ឋបាលដើម្បីជូនដំណឹងអំពីបញ្ហាផ្សេងៗ។ បញ្ហាផ្សេងៗទាំងនោះអាចមានដូចជា សកម្មភាពដែលកំពុងកើតមានឡើងនៅក្នុងមូលដ្ឋាន ឬ បញ្ហា ដែលទាក់ទងទៅនឹងព័ត៌មានថ្មីៗហើយមិនទាន់បានលើកយកមកពិភាក្សានៅក្នុងរបៀបនៃកិច្ចប្រជុំ ឧទាហរណ៍: ដំណើរទស្សនៈកិច្ចផ្លូវការរបស់គណៈប្រតិភូ ឬ កម្មវិធីអភិវឌ្ឍរបស់ម្ចាស់ជំនួយ ។<br>• កម្មវិធីសំណួរ ចម្លើយ និងការបញ្ចេញមតិយោបល់ ផ្តល់ឱកាសឱ្យ | សេចក្តីព្រាងរបៀបវារៈ<br><br>ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា (ផ្នែកទី២ ជំហានទី៨) |

| | | |
|---|---|---|
| | ប្រជាពលរដ្ឋ តំណាងសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការសួរសំណួរ និងផ្តល់យោបល់ត្រឡប់ភ្លាមៗទៅលើបញ្ហា ដែលបានពិភាក្សា និងសម្រេចនៅក្នុងដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ និងក្រុមគោលដៅព្រមព្រៀងលើសកម្មភាពដែលត្រូវអនុវត្ត នៅក្នុងកិច្ចប្រជុំលើកក្រោយ ។ | |
| **សង្ខេប និង សន្និដ្ឋាន (១០នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចរៀនសូត្រសំខាន់ៗ និងបញ្ជាក់ពីកម្មវិធីសម្រាប់ការប្រឹក្សាយោបល់លើកក្រោយ ។ | កម្មវិធីប្រឹក្សាយោបល់ |

## មេរៀនទី៨៖ កិច្ចប្រជុំសម្ងាត់ និងកិច្ចប្រជុំវិសាមញ្ញ

| | | |
|---|---|---|
| **ប្រធានបទ** | កិច្ចប្រជុំសម្ងាត់ និងកិច្ចប្រជុំវិសាមញ្ញ | សម្ភារៈ និងឯកសារយោង |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះក្រុមគោលដៅយល់ដឹងកាន់តែប្រសើរអំពីកិច្ចប្រជុំសម្ងាត់ និងកិច្ចប្រជុំវិសាមញ្ញ | |
| **ក្រុមគោលដៅ** | សមាជិកក្រុមប្រឹក្សាទាំងមូល និងនាយករដ្ឋបាល | |
| **រយៈពេល** | ១ម៉ោង៣០នាទី | |
| **ដំណើរការ (១ម៉ោង ១៥នាទី)** | **សេចក្ដីផ្ដើម (១០នាទី)**<br>កិច្ចប្រជុំរបស់ក្រុមប្រឹក្សាមាន២ប្រភេទគឺ កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។ កិច្ចប្រជុំទាំងនេះត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែក្រុមប្រឹក្សាអាចប្រជុំសម្ងាត់ក្នុងផ្នែកណាមួយនៃកិច្ចប្រជុំសាមញ្ញ ឬ កិច្ចប្រជុំវិសាមញ្ញបាន។ កិច្ចប្រជុំសម្ងាត់មិនត្រូវបានអនុញ្ញាតឱ្យសាធារណជនចូលរួមឡើយ។<br><br>**<u>កិច្ចប្រជុំសម្ងាត់</u>៖**<br>**សំណួរបំផុស (២៥នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរៈ<br>• ហេតុអ្វីបានជាក្រុមប្រឹក្សាត្រូវប្រជុំជាសម្ងាត់?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយទាំងអស់នៅលើក្រដាសផ្ទាំងធំ និងបញ្ជាក់ពីចំណុចនានាដែលមានចែងនៅក្នុងឯកសារបច្ចេកទេស (ផ្នែកទី២)។<br><br>**<u>កិច្ចប្រជុំវិសាមញ្ញ</u>៖**<br>**សំណួរបំផុស (៤០នាទី)**<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរៈ<br>• តើកិច្ចប្រជុំវិសាមញ្ញជាអ្វី ?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយទាំងអស់នៅលើក្រដាសផ្ទាំងធំ និងពន្យល់ថា កិច្ចប្រជុំវិសាមញ្ញ គឺជាកិច្ចប្រជុំ ដែលមិនបានគ្រោងទុកជាមុន ហើយមានគោលបំណងមួយ ឬ ច្រើន។<br>កិច្ចប្រជុំវិសាមញ្ញអាចមានគោលបំណងដើម្បីពិភាក្សាពីបញ្ហាបន្ទាន់ផ្សេងៗ (ឧទាហរណ៍ៈ បញ្ហាទឹកជំនន់ ជម្ងឺរាតត្បាត កង្វះស្បៀងអាហារ... ។ល។) | ច្បាប់រៀបចំអង្គការ មាត្រា៦៨, ៧៧, ១៥៧ អនុក្រឹត្យ២១៦ មាត្រា៧១, ៧៣, ៨៦, ១៣៣, ១៣៥, ១៤៧, បទបញ្ជាផ្ទៃក្នុង ប្រការ១, ៤, ២៤, ២៥, ៣០,<br><br>ឯកសារបច្ចេកទេស (ផ្នែកទី២) |

| | | |
|---|---|---|
| | ឬ អាចមានគោលបំណងដើម្បីពិភាក្សាពីបញ្ហាពិសេសណាមួយ (ឧទាហរណ៍៖ គម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា បញ្ហាហិរញ្ញវត្ថុ ឬ ផែនការរយៈពេល៥ឆ្នាំ ការធ្វើដីកា... ។ល។)<br><br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សួរសំណួរ៖<br>• តើលោកអ្នករៀបចំកិច្ចប្រជុំវិសាមញ្ញយ៉ាងដូចម្តេច?<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សរសេរចម្លើយទាំងអស់នៅលើក្រដាសផ្ទាំងធំ និងសង្ខេបចំណុចសំខាន់ដែលមានចែងនៅក្នុងឯកសារបច្ចេកទេស ។<br>មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់បញ្ជាក់ជាមួយក្រុមគោលដៅ ដើម្បីធានាថាពួកគាត់យល់បានច្បាស់ពីខ្លឹមសារនៃផ្នែកនេះ ។<br><br>**<u>កំណត់សំគាល់</u>** ៖ ដើម្បីធានានូវគុណភាពនៃការប្រឹក្សាយោបល់ មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់គួរចែកក្រុមប្រឹក្សាជាក្រុមតូចៗ ។ | សេចក្តីសង្ខេបស្តីពីកិច្ចប្រជុំវិសាមញ្ញ |
| **សង្ខេប និងសន្និដ្ឋាន (១៥នាទី)** | មន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់សង្ខេបចំណុចរៀនសូត្រសំខាន់ៗអំពីកិច្ចប្រជុំសម្ងាត់ និងកិច្ចប្រជុំវិសាមញ្ញ ។ | កម្មវិធីប្រឹក្សាយោបល់ |

## សេចក្តីសង្ខេបនៃកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា

- កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាគឺជាកិច្ចប្រជុំមួយដោយមិនមានកាលវិភាគច្បាស់លាស់ទេ ហើយការប្រជុំនេះមានគោលបំណងពីរសំខាន់ៗ ។ កិច្ចប្រជុំវិសាមញ្ញអាចមានគោលបំណងដើម្បីពិភាក្សាបញ្ហាបន្ទាន់ ឬ មានគោលបំណងដើម្បីពិភាក្សាបញ្ហាសំខាន់ណាមួយ ។

**តើកិច្ចប្រជុំវិសាមញ្ញត្រូវបានកោះប្រជុំយ៉ាងដូចម្តេច**

- កិច្ចប្រជុំវិសាមញ្ញត្រូវបានកោះប្រជុំដោយ ៖
    - ប្រធានក្រុមប្រឹក្សា ឬ
    - ចំនួនមួយភាគបី (១/៣)នៃសមាជិកក្រុមប្រឹក្សាទាំងអស់
- លើសពីនេះទៀតយោងតាមបទបញ្ជាផ្ទៃក្នុង អភិបាល ឬគណៈអភិបាលអាចស្នើកោះប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាបានដើម្បីពិភាក្សាលើបញ្ហាបន្ទាន់ណាមួយ ។

**កិច្ចប្រជុំវិសាមញ្ញអាចធ្វើឡើងជាសាធារណៈ**

ដូចកិច្ចប្រជុំសាមញ្ញដែរ កិច្ចប្រជុំវិសាមញ្ញត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែអាចធ្វើជាសម្ងាត់បានលុះត្រាតែមានហេតុផលសមស្រប ។

- លើសពីនេះទៀតត្រូវរកគ្រប់មធ្យោបាយក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីពីកិច្ចប្រជុំវិសាមញ្ញ ដើម្បីឱ្យសាធារណជនអាចចូលរួមសង្កេត និងពិភាក្សារាល់ការសម្រេចចិត្តលើបញ្ហានានា ។
- ក្នុងករណីមានបញ្ហាបន្ទាន់ណាមួយសំណូមពររាល់លិខិតអញ្ជើញ សេចក្តីព្រាងរបៀបវារៈ និងឯកសារពាក់ព័ន្ធត្រូវចែកជូនឱ្យបាន ២-៥ ថ្ងៃមុនកិច្ចប្រជុំវិសាមញ្ញចាប់ផ្តើម ។

**កិច្ចប្រជុំវិសាមញ្ញសម្រាប់បញ្ហាបន្ទាន់ណាមួយ**

- **បញ្ហាបន្ទាន់** គឺជាបញ្ហាដែលតម្រូវឱ្យមានសេចក្តីសម្រេចភ្លាមៗពីក្រុមប្រឹក្សា ដែលមិនអាចរង់ចាំកិច្ចប្រជុំសាមញ្ញបន្ទាប់របស់ក្រុមប្រឹក្សាបាន ដូចជាបញ្ហាគ្រោះធម្មជាតិ ។
- សម្រាប់កិច្ចប្រជុំវិសាមញ្ញទាក់ទងទៅនឹងបញ្ហាបន្ទាន់នានា ការផ្ញើជូនលិខិតអញ្ជើញដល់សមាជិកក្រុមប្រឹក្សាទាំងអស់ពុំអាចធ្វើទៅបានក្នុងរយៈពេលពីរថ្ងៃដូចដែលបានចែងនៅក្នុងគំរូបទបញ្ជាផ្ទៃក្នុង ដូចនេះការផ្តល់ព័ត៌មានអាចធ្វើឡើងតាមរយៈទូរស័ព្ទ និងមធ្យោបាយផ្សេងៗ ដែលមានរយៈពេលតិចជាងពីរថ្ងៃ ។

**កិច្ចប្រជុំវិសាមញ្ញដើម្បីពិភាក្សាលើបញ្ហាសំខាន់ៗណាមួយ**

- បញ្ហាសំខាន់ៗគឺជាបញ្ហា ដែលអាចប្រើពេលវេលាច្រើនក្នុងកិច្ចប្រជុំសាមញ្ញមានដូចជា:
    - ការរៀបចំផែនការយុទ្ធសាស្ត្រ និងយន្តការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
    - ការកែសម្រួលលើការទទួលខុសត្រូវ និងក្របខ័ណ្ឌការងាររបស់បុគ្គលិកទីចាត់ការ ឬការិយាល័យណាមួយដោយយោងតាមឯកសារផ្លូវច្បាប់ដែលមានជាធរមាន ។

- ការពិនិត្យ និងអនុម័តលើផែនការអភិវឌ្ឍ និងថវិការបស់ក្រុមប្រឹក្សា ។

របៀបវារៈគំរូស្ដីពីកិច្ចប្រជុំវិសាមញ្ញដើម្បីពិភាក្សាលើបញ្ហាសំខាន់ណាមួយ ឬ បញ្ហាបន្ទាន់ សូមមើលនៅក្នុងឯកសារបច្ចេកទេសពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា **សូមមើលឯកសារបច្ចេកទេសទំព័រទី៤៥ ដល់ទំព័រ៤៨**។